- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០.ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ១០០៤/ ០០៥ .ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក , ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

<u>សំរេច</u>

<u>មាត្រា១</u>: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ៨៧ លានរៀល (ប៉ែតសិបប្រាំពីរលានរៀលគត់) ពីជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច) មកជំពូក ១០ (បៀវត្ស និង ប្រាក់បំណាច់) របស់ក្រសួងទេសចរណ៍ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៤ ។

<u>មាត្រា២</u>: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់បើកប្រាក់បៀវត្សជូនថ្នាក់ដឹកនាំ និង មន្ត្រីរាជការ ឆ្នាំ ២០០៤ ។

<u>មាត្រា៣</u>: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :...៤២៦...អនក្រ-បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧, ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤, ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០.ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ១០០៤/ ០០៥ .ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក , ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

មាត្រា១: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ២១.២២៣ លានរៀល (ម្ភៃមួយពាន់ពីររយម្ភៃបីលានរៀលគត់) ពីជំពូក ៤០ (ចំណាយផ្សេងៗ) នៃខ្ទង់ចំណាយមិនទាន់បែងចែកចំនួន ៥.០០០ លានរៀល (ប្រាំពាន់លានរៀលគត់)និងពីជំពូក ៤១ (ចំណាយមិនបានគ្រោងទុក)នៃខ្ទង់ចំណាយមិនទាន់បែងចែកចំនួន ១៦.២២៣ លានរៀល (ដប់ប្រាំមួយពាន់ពីររយម្ភៃបីលានរៀលគត់) មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច) ចំនួន ១៩.៥៥០ លានរៀល (ដប់ប្រាំបួនពាន់ប្រាំរយហាសិបលានរៀលគត់) និងជំពូក ៣០ (អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច)ចំនួន ១.៦៧៣ លានរៀល (មួយពាន់ប្រាំមួយរយចិតសិបបីលានរៀលគត់) សំរាប់ ÷

- ទីស្តីការគណៈរដ្ឋមន្ត្រី ជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច) ចំនួន ១៥.៨២០ លានរៀល (ដប់ប្រាំពាន់ប្រាំបីរយម្ភៃលានរៀលគត់) សំរាប់ទូទាត់ថវិកាបុរេប្រទានឆ្នាំ ២០០៣ ចំនួន ៧.២២០ លានរៀល (ប្រាំពីរពាន់ពីររយម្ភៃលានរៀលគត់) ចំណាយការងារពិសេសរបស់រាជរដ្ឋាភិបាល ចំនួន ៦.២០០ លានរៀល (ប្រាំមួយពាន់ពីររយលានរៀលគត់),ចំណាយត្រៀមបំរុងអន្តរាគមន៍គ្រោះធម្មជាតិ ចំនួន ២.២០០ លានរៀល (ពីរពាន់ពីររយលានរៀលគត់) ,គណៈមេធាវីការពារជនក្រីក្រ ចំនួន ២០០ លានរៀល (ពីររយលានរៀលគត់) និងជំពូក ៣០ (អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច)ចំនួន ១.៦៧៣ លានរៀល (មួយពាន់ប្រាំមួយរយចិតសិបបីលានរៀលគត់) សំរាប់ទូទាត់ថវិកាបុរេប្រទានឆ្នាំ ២០០៣ ចំនួន ៧៣ លានរៀល (ចិតសិបបីលានរៀលគត់) និងចំណាយអាជ្ញាធរជាតិទេសចរណ៍ ចំនួន ១.៦០០ លានរៀល (មួយពាន់ប្រាំមួយរយលានរៀលគត់) សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤ ។
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច) ចំនួន ៣.៧៣០ លានរៀល (បីពាន់ប្រាំពីររយសាមសិបលានរៀលគត់) សំរាប់ពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ របស់ក្រសួង-ស្ថាប័នខាងលើ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់ទូទាត់ថវិកាបុរេប្រទាន ឆ្នាំ ២០០៣ ,ចំណាយការងារពិសេសរបស់រាជរដ្ឋាភិបាល ,ចំណាយត្រៀមបំរុងអន្តរាគមន៍គ្រោះធម្មជាតិ ,ចំណាយគណៈមេធាវីការពារជនក្រីក្រ ,ចំណាយអាជ្ញាធរជាតិទេសចរណ៍ នឹងចំណាយពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ,រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ,គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : [illegible] អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្តល់ឥណទានថវិកាបន្ថែម ជូនក្រសួង-ស្ថាប័ន សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤

****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧. ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤. ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ . ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០.ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ១០០៤/ ០០៥ .ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក , ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា១: ដោយអនុលោមទៅតាមមាត្រា ៤៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម លេខ ០១/នស/៩៣.ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ១៩៩៣ ត្រូវបានអនុញ្ញាតផ្តល់បន្ថែមឥណទានថវិកា ចំនួន ៥.២៩៤ លានរៀល (ប្រាំពាន់ពីររយកៅសិបបួនលានរៀលគត់) ទៅលើសៀវភៅថវិកា ចំនួន ០៥ ក្រសួង-ស្ថាប័ន សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤ ដូចខាងក្រោម ÷

- .អគ្គលេខាធិការដ្ឋានរដ្ឋសភា ចំនួន ៩០០ លានរៀល
- .ទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន ៣.២០៩ លានរៀល
- -ក្រសួងមហាផ្ទៃ (ផ្នែករដ្ឋបាលទូទៅ) ចំនួន ៦៦២ លានរៀល
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ១៨១ លានរៀល
- -ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ចំនួន ៣៤២ លានរៀល

មាត្រា២: ឥណទានថវិកាបន្ថែមដូចបានកំណត់ក្នុងមាត្រា ១ ខាងលើ ត្រូវបានបន្ថែមនៅជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់តូច) សំរាប់ផ្តល់ជូនចំនួន ០៥ ក្រសួង-ស្ថាប័ន ដើម្បីទូទាត់ថវិកាបុរេប្រទាន ពីឆ្នាំ ១៩៩១ ដល់ឆ្នាំ ២០០០ ។

មាត្រា៣: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខណ្ឌ និង វាក្យខណ្ឌ ត្រូវធ្វើឡើងដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

មាត្រា៤: ឥណទានថវិកាបន្ថែមនេះ ត្រូវបានរដ្ឋសភាពិនិត្យអនុម័តក្នុងច្បាប់ហិរញ្ញវត្ថុ នាពេលខាងមុខ កាលបើចំណាយសំរាប់ទូទាត់ថវិកាបុរេប្រទាន ពីឆ្នាំ ១៩៩១ ដល់ឆ្នាំ ២០០០ ត្រូវបានចប់សព្វគ្រប់ ។

មាត្រា៥: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី .រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ .អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា .រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ .រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៦៤៧ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការលុបឈ្មោះមន្ត្រីរាជការ ដែលទទួលមរណភាព

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/ រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០០២/២៨១ ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការតម្លើងឋានន្តរសក្តិ ជូនមន្ត្រីរាជការដែលស្ថិតនៅក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- យោងលិខិតបញ្ជាក់មរណភាពលេខ ៣០២ ឃ.រតន.ប ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៤
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : លុបឈ្មោះឯកឧត្តម **ស៊ូ ឈាក់វីយ៉ា** មន្ត្រីសាលាខេត្តបាត់ដំបង ឋានន្តរសក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ៦ ដែលបានទទួលមរណភាពកាលពីថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ២០០៤ ដោយរោគាពាធ ចេញពីក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣ (ដើម្បីអនុវត្ត)
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៤៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការប្រគល់ការកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាឱ្យដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យ លេខ ៦៣ អន.ក្រ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រង ការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរសក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនលោក **សរ សិទ្ធិ** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ១១ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឱ្យមកទទួលភារកិច្ច ជាអគ្គលេខាធិការរងទី ១ នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ ។

មាត្រា ២ : សាមីខ្លួនត្រូវបានទទួលប្រាក់បំណាច់មុខងារ ក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យ លេខ នស/រកត/១២ ០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។ ក្នុងរយៈពេលបំពេញភារកិច្ចថ្មីនេះ សាមីខ្លួនត្រូវដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ. ៧៤៩. អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី .

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា .

-តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ .—

ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនលោក **PADDY ROOME** ទីប្រឹក្សាអន្តរជាតិទទួលការងាររដ្ឋបាលមូលដ្ឋាន និង វិមជ្ឈការ ដែលបានចូលរួមសហការល្អ ក្នុងការរៀបចំច្បាប់ និង គោលនយោបាយវិមជ្ឈការ នៅព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២ .—

រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ...ថ្ងៃទី... ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)
- ដូចមាត្រា ១ និងមាត្រា ២ (ដើម្បីអនុវត្ត)
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៦៥០.អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយ សហមេត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម. សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី .

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា .

-តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ .—

ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនអស់លោក លោកស្រី ចំនួន ២៧ រូប ដែលមានស្នាដៃល្អ និងគុណបំណាច់ខ្ពស់ ចូលរួមសហការ អនុវត្តគំរោងកម្មវិធីបំរើឱ្យយុទ្ធនាការ ចុះសៀវភៅអ្នកបោះឆ្នោតបូលដ្ឋានចល័តទូទាំងព្រះរាជាណាចក្រកម្ពុជា ដូចមានរាយនាមខាងក្រោមនេះ :

១- លោក AQEEL AHMAD អ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិ ទទួលសំរបសំរួលខេត្តកណ្តាល

២- លោកស្រី AYESHA NOOR អ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិ ទទួលសំរបសំរួលខេត្តរតនគិរី

៣- លោកស្រី CHIYUKI INOUE អ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិ ទទួលសំរបសំរួលខេត្តកំពង់ស្ពឺ

៤- លោកស្រី CLAUDINE CHASSIGNEUX អ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិ ទទួលសំរបសំរួលខេត្តស្វាយរៀង

៥- លោក DAN RADULESCU អ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិ ទទួលសំរបសំរួលថ្នាក់តំបន់ ៣

៦- លោកស្រី ELENA FALCIOLA អ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិទទួលសំរបសំរួលក្រុងព្រះសីហនុ

៧- លោក FRANCIS DENTEH អ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិទទួលសំរបសំរួលខេត្តមណ្ឌលគិរី

៨- លោក GAUTAM GOPAL PRASAD អ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិ ទទួលសំរបសំរួលខេត្តក្រចេះ

៩- លោក HANIF KHAN អ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិទទួលសំរបសំរួលខេត្តពោធិ៍សាត់

១០- លោកស្រី IRINA DINCU អ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិ ទទួលសំរបសំរួលក្រុងភ្នំពេញ

១១- លោកស្រី IRIS FRIEDRICHS អ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិ ទទួលសំរបសំរួលថ្នាក់តំបន់ ២

១២- លោក JOHN NATHAN BANALYA អ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិ ទទួលសំរបសំរួល ខេត្តកំពង់ធំ

១៣- លោក JOSE REY ANTONIO PALICTE អ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិ ទទួលសំរបសំរួល ខេត្តកោះកុង

១៤- លោក KEN RIEBE អ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិ ទទួលសំរបសំរួលថ្នាក់តំបន់ ១

១៥- លោក RAJA IJAZ អ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិ ទទួលសំរបសំរួលខេត្តកំពត

១៦- លោក PATRICK MOSOLF អ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិ ទទួលសំរបសំរួលខេត្តកំពង់ចាម

១៧- លោក PETER LUIJKX អ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិទទួលសំរបសំរួលខេត្តព្រះវិហារ

១៨- លោកស្រី RUHIE SETH អ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិ ទទួលសំរបសំរួលក្រុងភ្នំពេញ

១៩- លោក SAMITHA HETTIGE អ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិទទួលសំរបសំរួលខេត្តបាត់ដំបង និង ក្រុងប៉ៃលិន

២០- លោកស្រី SANDRA CHESTNUTT អ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិ ទទួលសំរបសំរួល ខេត្តតាកែវ

២១- លោក SEBASTIAN CORONACION អ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិ ទទួលសំរបសំរួលខេត្តបន្ទាយមានជ័យ

២២- លោក SERGEY GOLOBEV អ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិ ទទួលសំរបសំរួលខេត្តស្ទឹងត្រែង

២៣- លោកស្រី SHEILA KAELA KAMBOBE អ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិ ទទួលសំរបសំរួល ខេត្តកំពង់ឆ្នាំង

២៤- លោក SHERRY DHAR អ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិ ទទួលសំរបសំរួលខេត្តកំពង់ចាម

២៥- លោក SUNTU BADGIE អ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិ ទទួលសំរបសំរួលខេត្តឧត្តរមានជ័យ

២៦- លោក THOMAS HRICKO អ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិ ទទួលសំរបសំរួលខេត្តព្រៃវែង

២៧- លោក TOMOYUKI TATSUMI អ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិ ទទួលសំរបសំរួល ខេត្តសៀមរាប

មាត្រា ២ _

រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ . ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៤

ហ៊ុន សែន

<u>កន្លែងទទួល</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (<u>ដើម្បីជូនជ្រាប</u>)*
- *ដូចមាត្រា ១ និងមាត្រា ២ (<u>ដើម្បីអនុវត្ត</u>)*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៥១ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

៖៚

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី .

-បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា .

-តាមសំណើរបស់អភិបាលខេត្តកណ្តាល

សម្រេច

មាត្រា១: ត្រូវបានបំពាក់**មេដាយការងារ**តាមលំដាប់ថ្នាក់ជូនមន្ត្រីរាជការ នាយទាហាននិង នាយនគរបាលចំនួន១១៣រូប ដែលមានស្នាដៃល្អ ក្នុងការចូលរួមកសាង និង អភិវឌ្ឍន៍មូលដ្ឋានស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម ៖

ក/មេដាយមាសការងារ :

១-ឯកឧត្តម	**ឯម**	**សំអាន**	រដ្ឋលេខាធិការក្រសួងមហាផ្ទៃ
២-ឯកឧត្តម	**លី**	**យ៉ាវ**	រដ្ឋលេខាធិការក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់
៣-ឯកឧត្តម	**អូន**	**ព័ន្ធមុនីរ័ត្ន**	រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
៤-ឯកឧត្តម	**ធុក**	**គ្រឿនវុទ្ធា**	អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន

៥-ឯកឧត្តម	មុត	ខៀវ	អនុរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា
៦-ឯ.ឧ -ឧ.ទោ	សែម	សុវណ្ណនី	មេបញ្ជាការរងវិស្វកម្ម អគ្គបញ្ជាការ នៃក្រសួងការពារជាតិ
៧ -លោក	គឹម	ស្រេង	សមាជិកអចិន្ត្រៃយ៍បក្សខេត្ត កណ្ដាល
៨-លោក	ចែម	វិសុទ្ធ	អភិបាលស្រុកខ្សាច់កណ្ដាល
៩- ឯកឧត្តម	វង្សី	វិស្សុត	អគ្គលេខាធិការរងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
១០-ឯកឧត្តម	ហង់ ជួន	ណារ៉ុន	អគ្គលេខាធិការ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
១១-ឯកឧត្តម	សុខ	ចិន្តា	អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
១២-ឯកឧត្តម	ជូ	វិជិត្ត	អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
១៣-ឯកឧត្តម	ចាន់	សុធី	ប្រធាននាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
១៤-ឯកឧត្តម	គឹម	សុតៈ	ជំនួយការសម្ដេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន**
១៥-ឯកឧត្តម	ហ៊ាន	សាហ៊ីប	អគ្គលេខាធិការរងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
១៦-ឯកឧត្តម	ឈៀង	យ៉ាណារ៉ា	អគ្គលេខាធិការរង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
១៧-ឯ.ឧ-ឧ.ត្រី	ស៊ុន	គឹមសឿន	នាយក នាយកដ្ឋានបំពាក់សំភារៈសឹកក្រសួងការពារជាតិ
១៨-ឧកញ៉ា	ឡូវ	ហ៊ីង	ប្រធានក្រុមហ៊ុនកំពង់ផែ ឫស្សីជ្រោយ ព្រះប្រសប់
១៩-លោក	ខៀវ	សុខណាត	អភិបាលរងស្រុកខ្សាច់កណ្ដាល
២០-លោក	គង់	សោភ័ណ្ឌ	អភិបាលរងស្រុកខ្សាច់កណ្ដាល
២១-លោក	អ៊ុំ	ចន	ប្រធានការិយាល័យអប់រំយុវជន និង កីឡាស្រុកខ្សាច់កណ្ដាល
២២-លោក	ស៊ីន្ធ	គីលឹម	អភិបាលរងស្រុកខ្សាច់កណ្ដាល
២៣-លោក	ម៉ី	វ៉ាន់	ប្រធាននាយកដ្ឋានឧស្សាហកម្ម ហិរញ្ញវត្ថុ
២៤-លោក	ឈឹម	សារ៉ែត	អនុប្រធានធនាគារជាតិ
២៥-លោក	វង់	សណ្ដាប់	អគ្គនាយកក្រុមហ៊ុនជាតិធានារ៉ាប់រង
២៦-លោក	ជាប	ជាវុធ	អនុប្រធានទី១ នាយកដ្ឋានលទ្ធកម្មសាធារណៈ
២៧-លោក	នេត	មុនី	អនុប្រធានទី១ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ
២៨-លោក	ឃុន	ហ្យុលីន	អនុប្រធាននាយកដ្ឋាន វិនិយោគ និង សហប្រតិបត្តិការ
២៩-លោក	នូវ	សុខសម្បត្តិ	អនុប្រធាននាយកដ្ឋានបុគ្គលិក
៣០-លោក	ណារុប	វណ្ណថារ៉ី	ប្រធាននាយកដ្ឋានរដ្ឋបាលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
៣១-លោក	អ៊ី	ឡាំថា	ប្រធានការិយាល័យ នាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ
៣២-លោក	ផាត់	គង់	អនុប្រធានការិយាល័យនាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ
៣៣-លោក	ថុង	សុខហ៊ាន	វេជ្ជបណ្ឌិត មន្ទីរពេទ្យព្រះកុសមៈ
៣៤-លោក	ថេត	សំណាង	អនុប្រធានការិយាល័យ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

៣៥-លោក	សុខ	សុផល	ព្រឹទ្ធបុរស មហាវិទ្យាល័យស្ថាបត្យកម្ម និងនគរូបវិទ្យា ក្រសួង វប្បធម៌ និង វិចិត្រសិល្បៈ
៣៦-ឧ.ត្រី	ធម្ម	ឆន	ប្រធាននាយកដ្ឋានស្ថាបនា ក្រសួងមហាផ្ទៃ
៣៧-វ.ឯក	ឌិន	ទ៉ាន់ដេន	ជំនួយការ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ
៣៨-វ.ឯក	សួន	គឹមស្រ៊ុន	ជំនួយការ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ
៣៩-វ.ឯក	ម៉ុន	សុវណ្ណ	ជំនួយការ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ
៤០-វ.ឯក	យន់	ខេង	ជំនួយការ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ
៤១-វ.ឯក	ឯម	ទិចត្រា	ជំនួយការ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ
៤២-វ.ឯក	ម៉ុំ	សារាន	ជំនួយការ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
៤៣-វ.ឯក	ឡុង	សារឿន	ជំនួយការ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
៤៤-វ.ឯក	សូ	ឈរាល់	អនុប្រធានអង្គភាពអន្តោគមន៍ ជនបរទេសក្រសួងមហាផ្ទៃ
៤៥-វ.ឯក	ពិន	ពិសិដ្ឋ	អនុប្រធាននាយកដ្ឋានជនបរទេស ក្រសួងមហាផ្ទៃ
៤៦-វ.ឯក	នូ	នឿន	អនុប្រធាននាយកដ្ឋានស្ថិតិ និងលិខិតឆ្លងដែនក្រសួងមហាផ្ទៃ
៤៧-វ.ឯក	មាស	ទិរិទ្ធ	ប្រធាននាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រគ្រឿងញៀនក្រសួងមហាផ្ទៃ
៤៨-លោកជំទាវ វ.ទោ ជួន	គីម		នាយកការិយាល័យ អគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ
៤៩-វ.ត្រី	ថុ	ស្រេង	នាយរងការិយាល័យ នាយកដ្ឋានជនបរទេស ក្រសួងមហាផ្ទៃ
៥០-វ.ត្រី	សំ	វណ្ណសិទ្ធ	នាយរងការិយាល័យ នាយកដ្ឋានជនបរទេស ក្រសួងមហាផ្ទៃ
៥១-លោក	ងីម	ចំនួសុខ	មន្ត្រីគណបក្សប្រជាជន ខេត្តកណ្តាល
៥២-លោក	អ៊ុំ	ធន	ប្រធានមន្ទីរសុខាភិបាល ខេត្តកណ្តាល
៥៣-លោក	ជួន	ម៉េងឡុង	ប្រធានមន្ទីរធនធានទឹក និង ឧតុនិយមខេត្តកណ្តាល
៥៤-លោក	ជឹម	សុខខុន	ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទខេត្តកណ្តាល
៥៥-លោក	ឆា	លាងហ៊ត	អនុប្រធានមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទខេត្តកណ្តាល
៥៦-លោក	គីង	វណ្ណះ	អនុប្រធានមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទខេត្តកណ្តាល
៥៧-លោក	ឃ្លាំង	វណ្ណឌុល	ប្រធានការិយាល័យជលផលខេត្តកណ្តាល
៥៨-លោក	យ៉ុន	យុទរិទ្ធ	នាយផ្នែករដ្ឋបាលព្រៃឈើ កណ្តាល
៥៩-លោក	ចាន់	គឿន	ប្រធានការិយាល័យសង្គមកិច្ចស្រុកខ្សាច់កណ្តាល
៦០-លោក	តែ	ម៉ិនសុខ	ប្រធានការិយាល័យកសិកម្មស្រុក ខ្សាច់កណ្តាល
៦១-លោក	ផេង	ឈីម	ប្រធានការិយាល័យសុខាភិបាលស្រុក ខ្សាច់កណ្តាល
៦២-លោក	សេង	សារុន	អនុប្រធានការិយាល័យសុខាភិបាលស្រុក ខ្សាច់កណ្តាល
៦៣-លោក	អេង	សេដ្ឋា	ប្រធានការិយាល័យវប្បធម៌និងវិចិត្រសិល្បៈស្រុកខ្សាច់កណ្តាល
៦៤-លោក	មាស	សេរីរិទ្ធ	នាយកវិទ្យាល័យ ហ៊ុនសែន ខ្សាច់កណ្តាល

៦៥-លោក	ទូ	យន់ហ៊ាង	មន្ត្រីសាលាស្រុកខ្សាច់កណ្ដាល
៦៦-លោក	គិក	សារី	អធិការនគរបាលស្រុក ខ្សាច់កណ្ដាល
៦៧-លោក	គិន	គីន	អធិការរងនគរបាលស្រុក ខ្សាច់កណ្ដាល
៦៨-លោក	ស៊ិន	សំ	មេបញ្ជាការផ្នែកសឹករងស្រុកខ្សាច់កណ្ដាល
៦៩-លោក	គង់	ឃឿន	អនុប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុកខ្សាច់កណ្ដាល
៧០-លោកស្រី	ខឹម	គីមណៃ	ប្រធានការិយាល័យកិច្ចការនារីនិងយុទ្ធជនពិការស្រុកខ្សាច់កណ្ដាល
៧១-លោក	យ៉ាន់	នុន	សមាជិកក្រុមប្រឹក្សាឃុំព្រែកតាមាក់
៧២-លោក	នោម	នាយ	មេឃុំរកាជន្លឹង
៧៣-លោក	ទើង	ហួ	មេឃុំបាក់ដាវ
៧៤-លោក	ម៉ើស	ស៊ីង	មេឃុំស្វាយរមៀត
៧៥-លោក	ម៉ៅ	សេង	មេឃុំកោះឧកញ៉ាតី
៧៦-លោក	ម៉ែន	គង់	ជំទប់ទី១ ឃុំវិហារសួគ៌

ខ/ មេដាយប្រាក់ការងារ :

១-លោក	ពូ	ឃុនសេង	អនុប្រធានមន្ទីរស្រុកខ្សាច់កណ្ដាល
២-លោក	ថេម	សេងអេង	គណនេយ្យករសាលាស្រុក ខ្សាច់កណ្ដាល
៣-លោក	លី	ឈាងស្រេង	ប្រធានការិយាល័យសាធារណៈការស្រុក ខ្សាច់កណ្ដាល
៤-លោក	ឡាយ	សេង	ប្រធានស្នាក់ការពន្ធដារស្រុក ខ្សាច់កណ្ដាល
៥-លោក	ខឹម	កែម	នាយករងវិទ្យាល័យ ហ៊ុនសែន ខ្សាច់កណ្ដាល
៦-លោក	ឈុំ	សេងលី	មន្ត្រីកសិកម្មស្រុកខ្សាច់កណ្ដាល
៧-លោក	ស៊ុន	ឡាយ	អនុប្រធានការិយាល័យស្ថិតិផែនការស្រុកខ្សាច់កណ្ដាល
៨-លោកស្រី	នាំ	វណ្ណា	អនុប្រធានការិយាល័យកិច្ចការនារី អតីតយុទ្ធជនស្រុកខ្សាច់កណ្ដាល
៩-វ.ត្រី	សាន	ស៊ីវត្ថា	នាយរងការិយាល័យនាយកដ្ឋានស្ថាបនាក្រសួងមហាផ្ទៃ
១០-វ.ត្រី	ឯម	វដ្ឋា	នាយរងការិយាល័យនាយកដ្ឋាននគរបាលសេដ្ឋកិច្ចក្រសួងមហាផ្ទៃ
១១-វ.ត្រី	គួន	សុគន្ធ	នាយរងការិយាល័យនាយកដ្ឋានផ្សព្វផ្សាយអប់រំក្រសួងមហាផ្ទៃ
១២-វ.ត្រី	នុច	យ៉ុន	នាយរងការិយាល័យ នាយកដ្ឋានបរទេសក្រសួងមហាផ្ទៃ
១៣-អនុ.ឯក	រស់	គី	នាយផ្នែកការិយាល័យកណ្ដាលនគរបាលអន្តរជាតិក្រសួងមហាផ្ទៃ
១៤-អនុ.ទោ	ពិន	សុខុន	នាយរងផ្នែក នាយកដ្ឋានអង្គរក្ស ក្រសួងមហាផ្ទៃ
១៥-អនុ.ទោ	ជុំ	ហេង	នាយរងផ្នែក នាយកដ្ឋានអង្គរក្ស ក្រសួងមហាផ្ទៃ
១៦-លោក	ម៉ម	ប៊ុន	នាយរងផ្នែក នាយកដ្ឋានផ្សព្វផ្សាយអប់រំក្រសួងមហាផ្ទៃ
១៧-លោក	ម៉េង	ឈាងហេង	មេឃុំវិហារសួគ៌
១៨-លោក	នាយ	សេន	មេឃុំព្រែកតាមាក់

១៩-លោក គង់ ឈឹម ជំទប់ទី១ ឃុំរកាជន្លឹង
២០-លោក សុខ មុត មេឃុំជ័យធំ
២១-លោក ជា លឹម មេឃុំស៊ីធរ
២២-លោក សន សឿន មេឃុំកំពង់ចំលង
២៣-លោក ខឹន ឡឿន មេឃុំព្រែកលួង
២៤-លោក ព្រួល ស៊ុន មេឃុំព្រែកតាកូវ
២៥-លោក រស់ សំអុល ប្រធានការិយាល័យរដ្ឋបាលសាលាស្រុក ខ្សាច់កណ្តាល
២៦-លោក សាន់ សារ៉េត ជំទប់ទី១ ឃុំកំពង់ចំលង
២៧-លោក ម៉េង សារិន អធិការរង នគរបាលស្រុក ខ្សាច់កណ្តាល
២៨-លោក ម៉ិច កេត នាយរងផ្នែករដ្ឋបាលព្រៃឈើកណ្តាល

គ/ មេដាយសិរីវឌ្ឍនៈ សំរិទ្ធ :

១-លោក ឆាំ គីមស្រ៊ឿន ប្រធានភ្នាក់ងារបរិស្ថានស្រុកខ្សាច់កណ្តាល
២-លោក ខឹម សំបូរ ប្រធានការិយាល័យ នគរូបនីយកម្ម និងសំណង់ស្រុកខ្សាច់កណ្តាល
៣-លោក គីម ជួយ ប្រធានការិយាល័យពត៌មានស្រុក ខ្សាច់កណ្តាល
៤-លោក ជា គីមឡេង ប្រធានការិយាល័យប្រៃសនីយ៍ស្រុក ខ្សាច់កណ្តាល
៥-លោក ហូ ចិន មន្ត្រីធនធានទឹកស្រុកខ្សាច់ កណ្តាល
៦-លោក ផុន ចិន មេឃុំសន្លុង
៧-អនុ.ទោ ប្រាក់ ចាន់សើ នាយផ្នែកការិយាល័យកណ្តាល នគរបាលអន្តរជាតិក្រសួងមហាផ្ទៃ
៨-អនុ.ទោ ធី សុគន្ធ មន្ត្រីនាយកដ្ឋានជនបរទេសក្រសួងមហាផ្ទៃ
៩-អនុ.ទោ ហេង ចាន់ថន មន្ត្រីនាយកដ្ឋានអង្គរក្ស

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៥២ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

៍៍

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/001 ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី .

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា .

-តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១. -

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និង ជូនសប្បុរសជន ដែលបានបរិច្ចាគធនធាន ជួយកសាងសមិទ្ធផលនានា ដូចជា ព្រះវិហារ ស្រះទឹក ដងទង់ និង ចាក់ដីបំពេញទីធ្លា វត្តចំបក់ ស្ថិតក្នុងឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល ដូចមានរាយព្រះនាម និង នាមខាងក្រោម :-

ក/មេដាយមាសស្ថាបនាជាតិ :

១-ព្រះតេជគុណ **គង់ សុធី**	ចៅអធិការវត្តចំបក់	បច្ច័យចំនួន ៨.000 ដុល្លារ និង ១២.000.000 រៀល
២-ឯកឧត្តម **មាស សុភា** និង លោក ជំទាវ **ឈរ ម៉ូ**		ថវិកា ចំនួន ៧.៥00 ដុល្លារ និង ១៩.000.000 រៀល

ខ/មេដាយប្រាក់ស្ថាបនាជាតិ :

១-ឯកឧត្តម **សេស ចន្ទសត្ថា**	នៅក្រុងភ្នំពេញ	ថវិកាចំនួន ៥.២៤៧ ដុល្លារ
២-លោក **ជីន ហ៊ាង**	នៅក្រុងភ្នំពេញ	ថវិកាចំនួន ៧.000 ដុល្លារ
៣-លោក **ឈី ចន្ទរ៉ា** និងអ្នកស្រី **ខូ សេង**	នៅក្រុងភ្នំពេញ	ថវិកា ចំនួន ៥.០៤៧ ដុល្លារ
៤-លោក **ពន ព្រួច** និងអ្នកស្រី **ឃឹម យឿន**	នៅសហរដ្ឋអាមេរិក	ថវិកា ចំនួន ៥.000 ដុល្លារ

៥-ឧបាសិកា **ចៀម នា** នៅក្រុងភ្នំពេញ ថវិកា ចំនួន ៤.០០០ ដុល្លារ និង ១២.០០០.០០០ រៀល

៦-លោក **សួខ សុខ** គណៈកម្មការវត្តចំបក់ ថវិកា ចំនួន ៣.២៤៧ ដុល្លារ និង ១១.០០០.០០០ រៀល

មាត្រា ២. -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួល បានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ៨ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល:</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ .

09-10

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៥៣ អនក្រ.បក

អនុក្រឹត្យ
ស្ដីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១. -

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន ១១គ្រឿង ជូនសប្បុរសជន ចំនួន ១១រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងព្រះវិហារ វត្តអាស្រមស្នាពីមុខ ឃុំព្រែកខ្ពប ស្រុកឯកភ្នំ ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោមនេះ :-

ក/មេដាយមាសស្ថាបនាជាតិ :

១-លោកជំទាវ **អ៊ុម រៃ** ភរិយា ឧកញ៉ា **ឆាន ម៉ឿន** ប្រធានអង្គការសប្បុរសជនខ្មែរ សហរដ្ឋអាមេរិក ថវិកា ចំនួន ១១.៥០០ ដុល្លារ

២-លោក **ថន ឆលី** និងអ្នកស្រី **ឃុន ជាទី** សប្បុរសជនខ្មែរ នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១១.០០០ ដុល្លារ

ខ/មេដាយប្រាក់ស្ថាបនាជាតិ :

-ឧបាសិកា **ទី សឿម** ថវិកាចំនួន ៦.៥០០ ដុល្លារ

គ/មេដាយសំរឹទ្ធស្ថាបនាជាតិ :

១-ឧបាសក **ទ៉ែ យឿន** និង ឧបាសិកា **ចាន់ សាន** សប្បុរសជនខ្មែរ នៅសហរដ្ឋអាមេរិក ថវិកាចំនួន ៣.០០០ ដុល្លារ

២-លោក **យី សេដា** និងអ្នកស្រី **អ៊ុំ ផារ៉ាវិជន** សប្បុរសជនខ្មែរ នៅសហរដ្ឋអាមេរិក ថវិកាចំនួន ២.៨០០ ដុល្លារ

៣-អ្នកស្រី	យូ សុខុម	សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក	ថវិកា ចំនួន	២.៧០០ ដុល្លារ
៤-ឧបាសក	អ៊ូច ម៉ុ		ថវិកា ចំនួន	២.៦០០ ដុល្លារ
៥-ឧបាសក	អរចេ រ៉េន		ថវិកា ចំនួន	២.៣០០ ដុល្លារ
៦-ឧបាសក	គិន សឿន		ថវិកា ចំនួន	២.២០០ ដុល្លារ
៧-ឧបាសក	រ៉េន រ៉ុត		ថវិកា ចំនួន	២.០០០ ដុល្លារ
៨-ឧបាសក	នូ សឿ		ថវិកា ចំនួន	១.៨០០ ដុល្លារ

មាត្រា២. -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

219-220

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៦៥៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែង នាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៥០១ /១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ .-

ត្រូវបានផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងលោកវរសេនីយ៍ឯក ប៉ែន ចិម្មុល អត្តលេខ ០៣៧៦ បច្ចុប្បន្នអនុប្រធាននាយកដ្ឋានសុខាភិបាល ទៅទីប្រឹក្សាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ទទួលបន្ទុកការងារប្រយុទ្ធ នឹងជំងឺអេដស៍ ។

មាត្រា ២ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សហ-រដ្ឋមន្ត្រី រដ្ឋមន្ត្រី. រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៦៥៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការអនុវត្តវិន័យនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ / ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/ រកម /០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ម្រេ ច

មាត្រា ១ ..

ត្រូវបានអនុវត្តនីវិន័យចំពោះលោកវរៈសេនីយ៍ឯក **ខុន គីមឆាត់** អត្តលេខ ០៣៦៤ មន្ត្រីបំរើការងារនៅអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ ដោយរូបភាពដកហូត ឋានន្តរសក្តិ និងបណ្តេញចេញពីក្របខ័ណ្ឌនគរបាលជាតិ ។

មូលហេតុ : បានបោះបង់ចោលការងារ ។

មាត្រា ២ ..

ប្រាក់បៀវត្សរ៍ របបឧបត្ថម្ភផ្សេងៗ និងក្របខណ្ឌត្រូវបានលុបឈ្មោះចេញពីក្របខ័ណ្ឌនគរបាលជាតិ ចាប់ពីខែ .... ឆ្នាំ ២០០.... នេះតទៅ ។

មាត្រា ៣ ..

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយ នឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤ ..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៤

ហ៊ុន សែន

__កន្លែងទទួល__

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៧៥៦ អនក្រ-តត

អនុក្រឹត្យ
ស្តីពី
ការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៥០១ /១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ម្រេ ច

មាត្រា ១ ..

ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូនលោកវរសេនីយ៍ទោ **ឈឹម ឈឿន** អត្តលេខ ០៩៧៩ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

មាត្រា ២ ..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ... ៨ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៦៥៧ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមុខតំណែងនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៥០១ /១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ :-

ត្រូវបានតែងតាំងមុខតំណែងលោកឧត្តមសេនីយ៍ត្រី មាឡ្យ យុទ្ធ អត្តលេខ ០០២១ ជាទីប្រឹក្សាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា ២ :-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ៩ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ.....១៥៨ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៛៘

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី .

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា .

-តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេនព្រះតេជគុណ **ម៉ែន យេន** ចៅអធិការ វត្ត អង្គក្តីចាស់ ដែលបានបរិច្ចាគបច្ច័យផ្ទាល់ព្រះអង្គ ចំនួន ២២.២៤០ ដុល្លារ និង បច្ច័យបានមកពីសប្បុរសជននានា ចំនួន ៧.៥៤៧ ដុល្លារ សំរាប់សាងសង់ សាលាបាលី ០១ខ្នង មានបណ្តោយ ១២ម៉ែត្រ ទទឹង ០៩ម៉ែត្រ និង កំពស់ ០៣ជាន់ ស្ថិតក្នុងវត្តអង្គក្តីចាស់ ឃុំវត្តអង្គខាងជើង ស្រុកបន្ទាយមាស ខេត្តកំពត ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួលៈ

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា ១ និង មាត្រា ២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

B 66

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៦៥៩...អនក្រ-បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

១៧

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី .

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តកំពត

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនក្រុមហ៊ុន ប៊ីចេង *AJINOMOTO WORKER'S UNION* សញ្ញា ចានក្រហម របស់ជប៉ុន ដែលបានផ្តល់ថវិកា ជួយសាងសង់ អគារសិក្សា ចំនួន០១ខ្នង បង្គន់អនាម័យ ០១ខ្នង ក្លោងទ្វារ ០១ និង ដងទង់ជាតិ ០១ ព្រមទាំងបំពាក់សម្ភារឹម គ្រប់ប្រភេទ ជូនសាលាបឋមសិក្សាមិត្តភាព អាជីណូម៉ូតូ ត្រពាំងឈូក ឃុំមានរិទ្ធ ស្រុកដងទង់ ខេត្តកំពត ចំណាយអស់ទឹកប្រាក់ចំនួន ៣២.៤៧០ ដុល្លារ ។

